# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BBI0080**

## សម្ភាសជាមួយឈ្មោះ សាន់ ស៊ីម ភេទ ស្រី អាយុ ៥២ឆ្នាំ

មុខងារខ្មែរក្រហមៈ ធ្វើស្រែ

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ

មានស្រុកកំណើតនៅៈ ភូមិត្រើយត្រឹង ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល

សព្វថ្ងៃរស់នៅភូមិអូរដារលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ស សេងគា

០០:៥១:៣០

**២២ទំព័រ**

សេងគា : បាទ!ជាដំបូងខ្ញុំសូមជំរាបសួរមីង ខ្ញុំបាទឈ្មោះ សេងគា ខ្ញុំម៉ោពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា បាទហើយខាងខ្ញុំម៉ោនេះសុំសម្ភាសន៍មីងហ្នឹងគឺមានការអនុញ្ញាតពីថ្នាក់លើម៉ោរហូតដល់ក្រោមនេះដើម្បីឲ្យពូប្រធានភូមិហ្នឹង ជួយណែនាំសុំមីងសម្ភាសន៍អី អញ្ចឹងហើយការសម្ភាសន៍របស់ខ្ញុំនេះគឺចង់បានបទសម្ភាសន៍របស់មីងហ្នឹងយកទៅប្រើប្រាស់ចងក្រងជាឯកសារប្រវត្តិសាស្ត្រអីអញ្ចឹង ឯកសារផ្សេងៗអត់មានពាក់ព័ន្ធខាងនយោបាយទេមីង អញ្ចឹងក៏សុំការអនុញ្ញាតពីមីងដែរ មីងយល់យ៉ាងម៉េចដែរ?

ស៊ីម : អត់អីទេអូន ។

សេងគា : អញ្ចឹងខ្ញុំក៏សុំស្គាល់ឈ្មោះមីងដែរ មីងឈ្មោះ?

ស៊ីម : ខ្ញុំឈ្មោះ សាន់ ស៊ីម ។

សេងគា : មីងអាយុ?

ស៊ីម : អាយុ៥២ឆ្នាំ ។

សេងគា : បាទនៅស្រុកកំណើត?

ស៊ីម : នៅភូមិត្រើយត្រឹង នៅឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ។

សេងគា : បាទ!អាស្រ័យដ្ឋានបច្ចុប្បន្ននៅភូមិអីដែរ?

ស៊ីម : នៅភូមិអូរដារលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។

សេងគា : បាទ!ភូមិអូរដារលើមីង?

ស៊ីម : ចា៎!

សេងគា ៖ ឃុំអីគេមិញមីង?

ស៊ីម ៖ ឃុំបឹងរាំង។

សេងគា ៖ ឃុំបឹងរាំង ស្រុកកំរៀង។ ឪពុកមីងឈ្មោះអីដែរមីង?

ស៊ីម ៖ សំ ហួរ នាមត្រកូលគាត់។

សេងគា ៖ ចុះម្ដាយឈ្មោះអីមីង?

ស៊ីម ៖ ប៉ែន អ៊ុង។

សេងគា ៖ ឥឡូវគាត់ស្លាប់?

ស៊ីម ៖ គាត់ស្លាប់អស់ហើយ។

សេងគា ៖ ស្លាប់អស់ហើយ ស្លាប់ពីសម័យណាទៅ?

ស៊ីម ៖ រដ្ឋកម្ពុជាយើងនេះ។

សេងគា ៖ អូ៎!ទើបតែស្លាប់ហើយ?

ស៊ីម ៖ ចា៎!ក្រោយរដ្ឋកម្ពុជាទេ។

សេងគា ៖ មុន ប៉ុល ពតទៀត?

ស៊ីម ៖ អត់ទេ!ទើមជា១០ឆ្នាំនេះទេ។

សេងគា ៖ បាទ!អញ្ចឹងមីងមានបងប្អូនប៉ុន្មាននាក់?

ស៊ីម ៖ ខ្ញុំមាន៥នាក់។

សេងគា ៖ មីងជាកូនទីប៉ុន្មានហើយមីង?

ស៊ីម ៖ កូនទី១។

សេងគា ៖ ជាកូនច្បងគេទៀត?

ស៊ីម ៖ ចា៎!

សេងគា ៖ អញ្ចឹងបងប្អូន៥នាក់នៅរស់ទាំងអស់ទេមីង?

ស៊ីម ៖ នៅរស់ទាំអស់។

សេងគា ៖ ចុះប្អូនទី២ឈ្មោះអីមីង?

ស៊ីម ៖ សាន់ ឡុង។

សេងគា ៖ ទី៣?

ស៊ីម ៖ សាន់ ហឿន។

សេងគា ៖ ទី៣មីង?

ស៊ីម ៖ សាន់ ធឿន សាន់ ថាចទី៥ ។

សេងគា ៖ សាន់ ថាច?

ស៊ីម ៖ ចាំ!

សេងគា ៖ បាទ!អញ្ចឹងក៏ចង់ដឹងជីវប្រវត្តិមីងកាលនៅពីក្មេងមីងបានធ្វើអីខ្លះ ហើយបានរៀននៅ ណា ហើយបន្ទាប់ម៉ោធ្វើអីទៀតមីង?

ស៊ីម ៖ ចាំ!ខ្ញុំកាលនៅវ័យកុមារខ្ញុំនៅរៀនថ្នាក់ទី១២ គឺថ្នាក់ទី១យើងឥឡូវហ្នឹង ។

សេងគា ៖ បាទ!រៀននៅណាមីង?

ស៊ីម ៖ រៀននៅសាលាព្រែកអំបិលហ្នឹង ។

សេងគា ៖ មីងរៀនបានដល់ថ្នាក់ទីប៉ុន្មានដែរមីង?

ស៊ីម ៖ រៀនបានត្រឹមថ្នាក់ទី៨ រដ្ឋប្រហារ ។

សេងគា ៖ ថ្នាក់ទី១២រហូតដល់ថ្នាក់ទី៨មីង?

ស៊ីម ៖ ចាំ!រដ្ឋប្រហារឆ្នាំ៧០ហ្នឹងទៅក៏យើងឈប់ទៅ ។

សេងគា ៖ ម៉េចទៀតទៅ?

ស៊ីម ៖ ក្រោយមកទៀតសង្គ្រាមយើង៥ឆ្នាំ សម័យអាមេរិចអូន ។

សេងគា ៖ អញ្ចឹងក៏ឈប់រៀនទៅមីង?

ស៊ីម ៖ ចាំ!

សេងគា ៖ ឈប់រៀនទៅមានរត់ទៅណាអត់ ឬក៏នៅហ្នឹងទេ?

ស៊ីម ៖ ជម្លៀសខ្លួនម៉ោខាងយើងស្រែ ម៉ោខាងយើងកំពង់ស្ពឺ ម៉ោខាងក្រោយម៉ោខាងលិចអី នេះ ខាងយើងភ្នំជីសូរភ្នំអីខាងកំពង់ស្ពឺនេះ ខាងខេត្តកំពង់ស្ពឺជម្លៀសម៉ោ ព្រោះអីនៅ ខាងព្រែកអំបិលហ្នឹងវាផ្សារ ដល់អញ្ចឹងគេហៅស្រោចស្រង់អីគេនោះ ជំនាន់៥ឆ្នាំ យើងនៅមានវៃជាមួយខ្មែរក្រហម ដល់អញ្ចឹងទៅជម្លៀសខ្លួនម៉ោខាងដីស្រែហ្នឹងអត់ ទាន់មានខ្មែរក្រហមទេ កាលហ្នឹងខ្មែរក្រហមហើយនឹង លន់ ណុលហ្នឹង សម័យ៥ឆ្នាំ គឺសម័យ លន់ ណុលហើយធ្វើសង្គ្រាមរំលំស្តេចនោះ ។

សេងគា ៖ បាទ!ទម្លាក់សម្តេចសីហនុ?

ស៊ីម ៖ ចាំ!អញ្ចឹងជម្លៀសខ្លួនម៉ោខាងកំពង់ស្ពឺ ម៉ោកំពង់ស្ពឺហ្នឹងអត់មានគ្រាប់ផ្លោងមានអីទេ ។

សេងគា ៖ អញ្ចឹងមីងកើតនៅ១៩០០ប៉ុន្មាន?

ស៊ីម ៖ ឆ្នាំ១៩៦៨ ។

សេងគា : មីងកើតនៅឆ្នាំ១៩៦៨ អញ្ចឹងដល់ពេលមីងចូលរៀនហើយ ឆ្នាំ៧០ ពេលដែលមានរដ្ឋប្រហារមីង គេជម្លៀសចេញម៉ង់មីង?

សុីម : ចា៎! យើងរត់ខ្លួនឯង អត់ចម្លៀសទេដកខ្លួនចេញខ្លួនឯងម៉ង់ ។

សេងគា : កាលហ្នឹងយើងរត់ចេញខ្លួនឯង អញ្ចឹងម៉ោជាមួយទាំងគ្រួសារទាំងអស់?

សុីម : ម៉ែពុកអីហ្នឹងម៉ោទាំងអស់ ។

សេងគា : កាលហ្នឹងរត់ម៉ោហ្នឹងជិះអីម៉ោ?

សុីម : ជិះទូកដរ ព្រោះកាលហ្នឹងទឹកឡើង ខែទឹកជិះទូកដរម៉ោដល់កំពង់ស្ពឺ គេហៅវត្តចារៗ បងប្អូនម្ដាយខ្ញុំនៅហ្នឹង ខ្ញុំម៉ោហ្នឹងបាន២-៣ឆ្នាំក៏ត្រឡប់ទៅស្រុកវិញ ហើយទឹកដីហ្នឹងក៏បានខាង គេហៅរំដោះខ្មែរក្រហមកាន់កាប់ទៅ យើងក៏នៅក្នុងដីរំដោះនោះទៅ ដីរំដោះដោយខ្មែរក្រហមកាន់កាប់ហ្នឹង ឯពួកលន់ ណុល ហ្នឹងក៏ថយចេះតែថយៗទៅ ខាងភ្នំពេញហើយ ទៅខាងព្រែកតូចព្រែកត្នោត ទៅលើអញ្ចឹងទៅ ទៅជិតឯភ្នំពេញ នោះទៅ ឯដីយើងចុះម៉ោក្រោមស្អាង កោះធំអីហ្នឹងគឺតំបន់ខ្មែរក្រហមហ្នឹងកាន់កាប់ ។

សេងគា : បាទ! អញ្ចឹងទាល់ពេលឆ្នាំ៧០ ហ្នឹងម៉ោមីងក៏បានភ័យគេទម្លាក់គ្រាប់បែកហ្នឹង?

សុីម : ចា៎! គ្រាប់ផ្លោង គ្រាប់បែក ។

សេងគា : មីងរត់ម៉ោខាង?

សុីម : ខាងកំពង់ស្ពឺ ។

សេងគា : កាលហ្នឹងនៅភូមិអីមីង?

សុីម : នៅភូមិខ្ពម ប៉ុនមិនដឹងឃុំអីទេ ។

សេងគា : គេហៅភូមិខ្ពម?

សុីម : ចា៎!

សេងគា : ស្រុកអីមីងចាំស្រុកទេ?

សុីម : ស្រុកបាទី ។

សេងគា : ស្រុកបាទី តាកែវ?

សុីម : អើស៎ស្រុកនេះទេ ស្រុកចារ វត្តចារទេ កាលហ្នឹងខ្ញុំនៅយូរហើយ ។

សេងគា : ភូមិមឿងចារ?

សុីម : មិនមែនមឿងចារទេ ។

សេងគា : អ៊ូ! វត្តចារ?

ស៊ីម : កាលហ្នឹងភូមិចារ ឃុំចារហ្នឹងម៉ង ។

សេងគា : តែអត់ដឹងស្រុកអីទេ?

ស៊ីម : ស្រុកហ្នឹងរស្រុកបាទីឬអីទេ ព្រោះអីឥឡូវនេះប្រែប្រួល កាលហ្នឹងយូរហើយ ។

សេងគា : តែមិនដឹងថានៅក្នុងខេត្តកំពង់ស្ពឺ?

ស៊ីម : ចា៎!ឥឡូវហ្នឹងនៅក្នុងកំពង់ស្ពឺហ្នឹងឯងវត្តចារហ្នឹង ។

សេងគា : បាទ!ពេលមីងរត់ម៉ោនៅកន្លែងហ្នឹងប្រហែលជាបានប៉ុន្មានថ្ងៃដែរ ប៉ុន្មានខែ ប៉ុន្មាន ថ្ងៃ?

ស៊ីម : យី!បាន១ឆ្នាំដែរហ្នឹង ។

សេងគា : អ៊ូ!បាន១ឆ្នាំដែរ ហើយមានផ្ទះ មានដីដែរនៅហ្នឹង?

ស៊ីម : ផ្ទះអ៊ុំខ្ញុំបង្កើតនៅហ្នឹង ។

សេងគា : នៅផ្ទះអ៊ុំ អ៊ុំឈ្មោះអីអ៊ុំ?

ស៊ីម : អ៊ុំឈ្មោះ អ៊ុំយ៉េ ប៉ែន យ៉េ ខាងម្ដាយខ្ញុំ ។

សេងគា : គាត់ឲ្យនៅនោះទៅ?

ស៊ីម : ចា៎!នៅជាមួយគាត់ ។

សេងគា : នៅនោះធ្វើអីដែរមីង?

ស៊ីម : ធ្វើស្រែជួយធ្វើស្រែគាត់អញ្ចឹងទៅ ហូបទាំងអស់គ្នាហ្នឹងទៅ ។

សេងគា : អ៊ូ!ធ្វើស្រែជាមួយគាត់នៅហ្នឹងប្រហែលជាបានប៉ុន្មានឆ្នាំមីង?

ស៊ីម : ប្រហែលជាប៉ុន្មានទេ ៣ឆ្នាំក៏អីទេ ។

សេងគា : អញ្ចឹងដល់៧៣មីង?

ស៊ីម : ចា៎!៧៣ត្រឡប់ម៉ោភូមិវិញ ក៏ប៉ុន្តែនៅជាយភូមិ អត់ហានចូលទៅក្នុងភូមិទេព្រោះអីខ្លាចថ្នល់ជាតិនោះផ្សារគេ ៧៣ម៉ោវិញ ។

សេងគា : ៧៣ត្រឡប់ម៉ោវិញ?

ស៊ីម : ចា៎!ត្រឡប់ម៉ោវិញនៅចុងភូមិនេះ ។

សេងគា : នៅចុងភូមិមីងហ្នឹង?

ស៊ីម : ចុងភូមិហ្នឹងក៏ភូមិត្រើយត្រឹងហ្នឹងដែរ ទៅនៅខាងចំការៗស្វាយ ។

សេងគា : បាទ!ម៉េចបានអត់ហាននៅភូមិ?

ស៊ីម : អត់ហាននៅក្នុងភូមិព្រោះវាជាប់ផ្សារ យន្តហោះទម្លាក់នៅជិតផ្សារ យន្តហោះទម្លាក់ធុងសាំងធុងអីហ្នឹងតែតាមផ្សារ តាមប្រជុំជនទេ ហើយដឹងខ្ញុំខ្លាចអញ្ចឹងក៏នាំ ម៉ែពុកហ្នឹងក៏នាំកូនចៅម៉ោនៅចុងភូមិព្រោះចំការវាអត់ទម្លាក់ទេ វាទម្លាក់តែតាមថ្នល់ជាតិ ។

សេងគា : ដល់ពេលមីងថាអញ្ចឹងទៅក៏នាំគ្រួសារអីទៅនៅចំការស្វាយទាំងអស់គ្នាទៅមីង?

ស៊ីម : ចា៎! នៅមានបងប្អូនយើងជិតខាងហ្នឹងដកខ្លួនម៉ោពីខាងក្នុងភូមិហ្នឹងដែរ ។

សេងគា : បាទ! នៅគ្នាច្រើនទេកាលហ្នឹងមីង?

ស៊ីម : ប្រហែលជា៧-៨គ្រួសារតែប៉ុនហ្នឹងទេ ។

សេងគា : អ៊ូ! អញ្ចឹង ដល់នៅហ្នឹងទៅនៅបានរយៈពេលប៉ុន្មានបានមីងចូលផ្ទះវិញឬក៏រត់ទៅណាទៀត?

ស៊ីម : នៅរយៈពេលបាន២ឆ្នាំនៅចំការស្វាយហ្នឹង ជាមួយបងប្អូនយើង៧-៨គ្រួសារហ្នឹង ប្រហែលជា៧៣-៧៥ ៧៥ម៉ោនៅកន្លែងផ្ទះដដែលវិញ ។

សេងគា : អ៊ូ! នៅបាន២ឆ្នាំ?

ស៊ីម : ចា៎! នៅបាន២ឆ្នាំចូលម៉ោនៅកន្លែងផ្ទះដដែលវិញ ។

សេងគា : ៧៥បានហានម៉ោនៅក្នុងផ្ទះវិញ?

ស៊ីម : ចា៎! នៅផ្ទះហ្នឹងក៏ខ្ញុំបាន៧៥ហ្នឹង ។

សេងគា : មីងកាលហ្នឹងអាយុប៉ុន្មានហើយ?

ស៊ីម : អាយុបាន១៨ហើយ ហើយក្នុងពេល៧៥ហ្នឹងខ្ញុំបានចេញទៅនៅអង្គភាពហើយ បានម៉ោនៅផ្ទះហើយចេញទៅនៅអង្គភាពស្រែអំបិលយើង ប៉ុន្តែម៉ោនៅកំពតនេះ អង្គភាពរដ្ឋ ។

សេងគា : អអញ្ចឹងមានន័យថាឆ្នាំ៧៥ហ្នឹងមីងត្រឡប់ម៉ោភូមិវិញ បានប៉ុន្មានថ្ងៃទៅវិញទៀត?

ស៊ីម : ប្រហែលជា២ខែដែរ យូរដែរ ព្រោះអីយើង៧៥ហ្នឹងមិនរំដោះភ្នំពេញហើយ ហើយខ្ញុំជាអ្នកមូលដ្ឋាននៅហ្នឹងទេ ខ្ញុំមិនជាអ្នកជម្លៀសពីភ្នំពេញពីអីទេ ដល់អញ្ចឹងក៏គេត្រូវការអង្គភាពយើងខ្មែរក្រហមហ្នឹង៣ឆ្នាំហ្នឹង ៣ឆ្នាំហ្នឹងមិនកាន់កាប់ដោយប៉ុល ពត ។

សេងគា : បាទ!

ស៊ីម : ចា៎! ក៏នៅផ្ទះបាន២-៣ខែហ្នឹងក៏ត្រូវការជ្រើសរើសទៅអង្គភាពស្រែអំបិល នៅបំរើការងារដូចជា កាលហ្នឹងយុវវ័យគឺមិនបាននៅផ្ទះទេ ច្រើនតែទៅធ្វើការងារបំរើអង្គភាព

ខ្លះទៅកាត់ដេរ ខ្លះទៅស្រែអំបិលខ្លះទៅកំពង់សោមអីអញ្ចឹងទៅ ដោយឡែកខ្ញុំមានមុខទៅខាងស្រែអំបិលរដ្ឋនៅខាងត្រើយកោះ ។

សេងគា ៖ មីងខ្ញុំសូមសារក្រោយបន្តិច មិញមីងថាកាល៧៥ហ្នឹងមីងទៅគេរើសទៅ?

ស៊ីម ៖ ចា៎!

សេងគា ៖ គេរើសទៅអង្គភាពស្រែអំបិល អង្គភាពហ្នឹងអ្នកណាគេអ្នករើសមីង?

ស៊ីម ៖ ខាងយើងប៉ុល ពតនោះ ប៉ុល ពតគេមិនមានបណ្តាញ ។

សេងគា ៖ ពួកខ្មែរក្រហម?

ស៊ីម ៖ ចា៎!

សេងគា ៖ កងឈ្លប ឬក៏?

ស៊ីម ៖ អត់ទេ!ខាងមន្ទីរ ដូចយើងភូមិឃុំអញ្ចឹង ប៉ុន្តែយើងមានមន្ទីរឃុំគេ មានភូមិមានឃុំដូចគ្នាដូចឥឡូវនេះអញ្ចឹង មានស្រុកដូចគ្នា ខាងមន្ទីរស្រុករើសទៅ ចូលទៅក្នុងអង្គភាព រដ្ឋ ។

សេងគា ៖ មីងមានចាំថាអ្នកណាម៉ោរើសម៉ោហៅទៅទេមីង?

ស៊ីម ៖ ដូចមិនបានចាំទេ ព្រោះអីតាមរយៈភូមិឃុំគេ ។

សេងគា ៖ ដឹងតែតាមភូមិឃុំគេចាត់តាំងមីង?

ស៊ីម ៖ ចា៎ៗ!ឲ្យតាមភូមិហ្នឹងគេជ្រើសរើសទៅ ។

សេងគា ៖ ម៉េចបានគេចាត់តាំងមីងឲ្យធ្វើខាងអង្គភាព?

ស៊ីម ៖ ព្រោះគេថា ដូចថាជួយកសាងជាតិ ព្រោះយើងបានរំដោះពីដូចថាជំនាន់ហ្នឹងគេថាអាណានិគមម៉េចគេនោះ ដូចយើងបានរំដោះអញ្ចឹងទៅពីវណ្ណៈជិះជាន់អីអញ្ចឹងទៅ ដល់ហើយយើងត្រូវជ្រើសរើសយកកម្លាំងយុវជនយុវនារីហ្នឹងចូលក្នុងអង្គភាពដើម្បីជួយកសាងជាតិ ព្រោះទើបនឹងរួចពីសង្គ្រាម៥ឆ្នាំ ។

សេងគា ៖ អញ្ចឹងមីងទៅតែឯងឬមានបងប្អូនទៅជាមួយឪពុកម្តាយអី?

ស៊ីម ៖ បងប្អូនបង្កើតអត់ទេ ខ្ញុំទៅតែខ្ញុំទេ ទៅតាំងពីអាយុដែលពេញវ័យ ។

សេងគា ៖ យុវជន?

ស៊ីម ៖ ចា៎!យុវវ័យទេ ។

សេងគា ៖ អញ្ចឹងប្អូនមីងនៅក្មេង?

ស៊ីម ៖ ចា៎!នៅក្មេងៗ ។

សេងគា ៖ ហើយឪពុកម្តាយអត់ទៅទេមីង?

ស៊ីម : អត់ទេ!

សេងគា : ទៅតែកម្លាំងនៅពេញ?

ស៊ីម : ចា៎!កម្លាំងយុវនារីទេ ។

សេងគា : ទៅមានគ្នាច្រើនទេ ភូមិភាគគេមីង?

ស៊ីម : មានៗ អ្នកភូមិជាយុវនារីដូចៗគ្នាហ្នឹង ប៉ុន្តែជ្រើសទៅតាមភូមិ ហៅទៅប្រជុំ ។

សេងគា : ម៉ាភូមិយកប្រហែលប៉ុន្មាននាក់មីង?

ស៊ីម : ហៅទៅប្រជុំទៅគេតម្រូវការម៉ាភូមិ២-៣នាក់អញ្ចឹង ។

សេងគា : ប្រជុំគេនិយាយប្រាប់មីង?

ស៊ីម : ចា៎!

សេងគា : គេនិយាយប្រាប់ថាម៉េចខ្លះទៅមីង?

ស៊ីម : គេថាឲ្យយើងជួយកសាងជាតិ ព្រោះយើងជាយុវជនយុវនារីមានកម្លាំងជាស្នូលអញ្ចឹង ទៅណា៎ រួមចំណែកជួយកសាងប្រទេស ។

សេងគា : ចុះម៉ាក្រុមមីងដែលទៅហ្នឹងមានគ្នាប៉ុន្មាននាក់ ដែលនៅស្រែអំបិលហ្នឹង ។

ស៊ីម : គ្នាក្នុងម៉ាស្រុកហ្នឹង៣០នាក់ ម៉ាស្រុកដែលត្រូវការទៅ ។

សេងគា : មានសាល់ឈ្មោះ១នាក់ ២នាក់ទេដែលទៅជាមួយហ្នឹង?

ស៊ីម : ដូចជាភ្លេចអស់ហើយយូរហើយ ។

សេងគា : ភ្លេចហើយ តែដឹងតែថាប្រហែល៣០នាក់មីង?

ស៊ីម : ចា៎!ហៅយកសុទ្ធតែស្រីទេ អត់យកប្រុសទេ ។

សេងគា : ស្រីទៅសុទ្ធ?

ស៊ីម : ចា៎!អង្គភាពស្រែអំបិលសុទ្ធតែស្រី អត់មានប្រុសទេ ប្រុសមាន១នាក់ ២នាក់គាត់ចេះធ្វើបច្ចេកទេសធ្វើអំបិលធ្វើបច្ចេកទេសធ្វើម៉ាស៊ីន ឯកម្លាំងធំគឺស្រី ។

សេងគា : ហើយនៅពេលដែលគេឲ្យទៅអញ្ចឹងមីងមានប្រកែកអីដែរ ឬចង់ទៅម៉ង?

ស៊ីម : ដូចសប្បាយម៉ងអូន អត់មានប្រកែកទេ ។

សេងគា : ពុះកញ្ជ្រោលចង់ទៅម៉ង?

ស៊ីម : ចា៎!ហ្នឹងព្រោះអីយើងមានចិត្តមួយ យើងអត់បានធ្វើកងទ័ពយើងឯករាជហើយ នឹកឃើញអញ្ចឹង ឯករាជហើយត្រូវជួយកសាងទៅទាំងគេទាំងយើងហ្នឹង អត់មាននឹក

ឃើញម្តាយ នឹកឃើញបងប្អូនអីវាងសប្បាយ ដល់ទៅដល់អន្តរភាពបែកឪពុកម្តាយយូរខែវាងនឹងដែរហ្នឹង ។

សេងគា ៖ បាទ! ដល់ទៅពីនេះគេដឹកឡានទៅមីង?

ស៊ុម ៖ ចាំ!ជិះរទេះភ្លើងទៅហ្នឹង ។

សេងគា ៖ ចុះអ្នកណាគេអ្នកចាត់តាំង មីងមានស្គាល់នរណាគេម្នាក់ដែលចាត់តាំងឲ្យមីងឡើងឡានអ្នកណាគេ មីងស្គាល់ទេ ប្រធានភូមិឬក៏ម៉េច?

ស៊ុម ៖ អេស៎!មិនស្គាល់ឈ្មោះ មេភូមិហ្នឹងឈ្មោះ កុយ ឈុម ប្រធានភូមិកាលដែលខ្ញុំទៅហ្នឹង ។

សេងគា ៖ ឥឡូវគាត់ស្លាប់ឬរស់ឥឡូវ?

ស៊ុម ៖ ខ្ញុំខានទៅស្រុកយូរហើយ កាល ។

សេងគា ៖ ប៉ុន្តែកាល៧៩ហើយ គាត់នៅរស់ទេមីង?

ស៊ុម ៖ ចាំ!គាត់នៅរស់ទេ ។

សេងគា ៖ គាត់ជាមនុស្សម៉េចដែរមីង?

ស៊ុម ៖ មនុស្សគាត់ស្លូតបូត មានអីប្រជាជនស្រឡាញ់គាត់ រាប់អានគាត់ ។

សេងគា ៖ ដល់គេឲ្យកាន់ ក៏អញ្ជើញមីងឲ្យម៉ោនេះទៅ?

ស៊ុម ៖ ចាំ!

សេងគា ៖ មីងនៅពេលដែលចេញពីហ្នឹងម៉ោប្រហែលរយៈពេលប៉ុន្មានថ្ងៃបានដល់?

ស៊ុម ៖ ១ថ្ងៃដល់កំពត ។

សេងគា ៖ ១ថ្ងៃម៉ោដល់ ហើយនៅពេលដែលដល់គេឲ្យមីងនៅធ្វើអី?

ស៊ុម ៖ ម៉ោដល់នៅក្នុងក្រុង ក្នុងកងហ្នឹងអត់ទាន់ឲ្យធ្វើអីទេ កំឡុង២-៣ថ្ងៃអញ្ចឹងយើងហៅប្រជុំចងក្រងជាក្រុម ជាកងហា កងរយអញ្ចឹងទៅ ក្នុងមួយក្រុមមានពាកងហាអញ្ចឹង ទៅពាកងហាមានម៉ាកងរយ ។

សេងគា ៖ ម៉ាកងហាមានប៉ុន្មាននាក់មីង?

ស៊ុម ៖ ម៉ាកងហាពី៤០ទៅ៥០នាក់ ។

សេងគា ៖ ពី៤០ទៅ៥០នាក់ ប៉ុន្តែពាកងហ្នឹងប៉ុនបានម៉ាកងរយ?

ស៊ុម ៖ ចាំ!

សេងគា ៖ អញ្ចឹងមានតែម៉ាកងរយមានប្រហែល១៥០នាក់?

ស៊ីម : ១០០ឬក៏មិនដល់១០០ក៏គេអាចថាកងវរយបានដែរ ព្រោះអីមនុស្សនៅក្នុងកងវាមិនអាចគ្រប់ចំនួនទេ ប៉ុន្តែមេដឹកនាំសល់ពីយើងកាលតស៊ូនោះ សុទ្ធតែមេដឹកនាំនៅក្នុងអង្គភាពទ័ព ដល់អញ្ចឹងយកពីទ័ពហ្នឹងម៉ោរំសាយពីទ័ពម៉ោវាមានដឹកនាំច្រើន អញ្ចឹងចែករំលែកភារៈកិច្ចហ្នឹងតតាំងពីយើងតស៊ូអញ្ចឹងម៉ោ ដល់ពេលសម័យក៏សាងត្រូវយកអ្នកដឹកនាំហ្នឹងទៅធ្វើជាអ្នកដឹកនាំនៅក្នុងក្រុម ក្នុងកងហ្នឹងទៀត អញ្ចឹងវាត្រូវការមនុស្សប្រហែលជា៣០នាក់ក៏អាចជាកងហាបានដែល មិនចាំបាច់ដល់៥០ឬ៤៥ទេ ។

សេងគា : បាទ!អញ្ចឹងឲ្យតែពេលឡើងទៅគេហៅកងវរយមីង?

ស៊ីម : ចា៎!

សេងគា : ហើយកាលហ្នឹងមីងស្ថិតនៅក្នុងកងណាដែលមីង?

ស៊ីម : ខ្ញុំស្ថិតនៅក្នុងកងហាទី២ ។

សេងគា : កងហាទី២ មានគ្នាប្រហែលប៉ុន្មាននាក់?

ស៊ីម : មានគ្នា កាលហ្នឹងប្រហែលជា៣០នាក់ទេ មិនដល់ជា ។

សេងគា : អ្ហូ!៣០នាក់ដែលទៅពីភូមិមីងទៅហ្នឹងឬម៉េច?

ស៊ីម : អត់ទេ!មានអតីតទ័ព ទ័ពនារីយើង អូនមិនអាចកើតទាន់ថាមិនដឹងចុះណា៎ មានកងនារីបាញ់កាំភ្លើងដូចកងយុវជនអញ្ចឹង មានខាងកងនារីហ្នឹងផង មានខាងកាត់ដេរផងនោះ ផងដូចថាចំរាញ់ពីភូមិនេះទៅផង ពីកាត់ដេរទៅផងពីទ័ពនោះទៅផង ហើយតួនាទីអ្នកដឹកនាំគឺមានខាងនារីខាងទ័ពហ្នឹង មានដឹកនាំធ្វើជាក្រុមធ្វើជាកងហា ឯពួកខ្ញុំទៅពីភូមិពីស្រុកនេះអត់ទេ ជាកូនក្រុមរបស់គាត់ទេ ព្រោះគាត់មានភារៈកិច្ចចូលសមរភូមិអី មានស្មារតីក្លាហានណាស់ បាញ់ចូលសមរភូមិប្រយុទ្ធ អញ្ចឹងវាមានអតីតភាព អាចមានតួនាទីបានឬក៏ភ្ជាប់ពីទ័ពហ្នឹងម៉ោផង ។

សេងគា : ចុះមីងបានស្គាល់ឈ្មោះប្រធានកងហាទេមីង ឈ្មោះអីមីង?

ស៊ីម : ឈ្មោះគាត់ ។

សេងគា : កងហាហ្នឹងកងហាទី២?

ស៊ីម : ចា៎!កងហាទី២ ឈ្មោះមិនដឹងស្អីផលទេ ។

សេងគា : ឈ្មោះ មិត្តផល?

ស៊ីម : ចា៎!ឈ្មោះ ផល ។

សេងគា : គាត់ហ្នឹងជាមនុស្សម៉េចដែលមីង?

ស៊ឹម ៖ គាត់ មនុស្សគាត់អតីតខាទ័ពនារី គាត់ស្លូតបូតអត់អីទេ មិនមានកោងកាចមិនមានស្តី បន្ទោសកូនកងទេ ប៉ុន្តែគាត់ម៉ឺមាត់ក្នុងការងារ សុភាពរាបសា តែម៉ឺងម៉ាត់ ។

សេងគា ៖ ចុះអនុឈ្មោះអីដែលមីង អនុកងហាអីហ្នឹង?

ស៊ឹម ៖ មិនអាចចាំបានទេ ។

សេងគា ៖ ចុះកាលហ្នឹងមីងគេឲ្យមីងធ្វើអីមីង?

ស៊ឹម ៖ ខ្ញុំជាមហាជនសុទ្ធសាធ មិនមានតួនាទីអីទេ ធ្វើជាសមាជិកនៅក្នុងក្រុមហ្នឹង ធ្វើអំបិល វែក ធ្វើស្រែអំបិល ។

សេងគា ៖ សមាជិកនៅធ្វើអំបិល គេឲ្យឲ្យធ្វើអំបិល?

ស៊ឹម ៖ ចាំ!កម្មករធ្វើអំបិល ។

សេងគា ៖ នៅកំពតហ្នឹងកន្លែងធ្វើស្រែអំបិលហ្នឹងនៅភូមិអីគេមីង មានចាំភូមិទេ?

ស៊ឹម ៖ ភូមិត្រើយកោះ ភ្នំត្រើយកោះ ។

សេងគា ៖ ភូមិភ្នំត្រើយកោះ?

ស៊ឹម ៖ ចាំ!ភូមិត្រើយកោះ ។

សេងគា ៖ ឃុំអីកាលហ្នឹង?

ស៊ឹម ៖ មិនដឹងឃុំអីទេ ។

សេងគា ៖ អត់ចាំទេ នៅស្រុកស្រែអំបិល?

ស៊ឹម ៖ ស្រុកស្រុកកំពតហ្នឹង ខេត្តកំពតហ្នឹង ។

សេងគា ៖ នៅកន្លែងហ្នឹងគេហៅស្រែអំបិលហ្នឹង?

ស៊ឹម ៖ ស្រែអំបិល ត្រើយកោះ ។

សេងគា ៖ បាទ!នៅនៅហ្នឹងនៅធ្វើស្រែអំបិលហ្នឹងបានប្រហែលជាប៉ុន្មានខែ ប៉ុន្មានឆ្នាំទៅ?

ស៊ឹម ៖ មើស!តាំងពី៧៥រហូតដល់៧៩ ។

សេងគា ៖ អ្ហ៎!រហូតដល់៧៩មីង?

ស៊ឹម ៖ ចាំ!

សេងគា ៖ អញ្ចឹងនៅហ្នឹងបានជិត៣ឆ្នាំមីង?

ស៊ឹម ៖ ៧៩រត់យួនហ្នឹង ។

សេងគា ៖ បាទ!ដល់ពេល៧៩ហើយ ពេលវៀតណាមចូលម៉ោក៏នាំគ្នារត់ទៅមីង?

ស៊ីម : ចាំ!រត់ចេញម៉ោ ម៉ោខាងក្រៅនេះ ម៉ោក្រោមនេះ ម៉ោខាងពាយ័ព្យនេះ អត់មានចូលទៅកើតទេ ម៉ោលិច ។

សេងគា : ចុះកាលហ្នឹងមីងមានស្គាល់មិត្ត២-៣នាក់ធ្លាប់ធ្វើការជាមួយមីងទេ?

ស៊ីម : នៅក្នុងអន្តភាពស្រែអំបិលហ្នឹង?

សេងគា : បាទ!

ស៊ីម : មាន ប៉ុន្តែមានត្រកូលភ្លេចនាមត្រកូលអស់ហើយវាយូរហើយ ។

សេងគា : បាទ!ហើយឈ្មោះអីខ្លះ?

ស៊ីម : ឈ្មោះ ផាត់ ឡើងទៅជាមួយស្រុកខ្ញុំដែរ ។

សេងគា : នៅក្នុងភូមិជាមួយគ្នាមីង?

ស៊ីម : ឃុំជាមួយគ្នា ឃុំផ្សេងគ្នា ។

សេងគា : មានអ្នកណាទៀតមីង?

ស៊ីម : ឈ្មោះ យ៉ាន ។

សេងគា : ឈ្មោះ យ៉ាន អត់នៅជាមួយគ្នាទេមីង ឬនៅផ្សេងគ្នា?

ស៊ីម : នៅផ្សេងគ្នា ប៉ុនទៅក្នុងឃុំជាមួយគ្នា ឈ្មោះអីទៀតទេ ។

សេងគា : បាទ!ហើយគាត់២នាក់ហ្នឹងនៅរស់ទេ ឬក៏ស្លាប់ហើយ?

ស៊ីម : នៅរស់ទាំង២នាក់ ១នាក់នៅឯព្រំដែននេះ ១នាក់ទៀតនៅឯស្រុកកំណើតឃុំព្រែកអំបិលនោះ គេទៅព្រែកអំបិល ។

សេងគា : ព្រំដែនឡែនមីង?

ស៊ីម : ចាំ!

សេងគា : ចុះឈ្មោះ ផាត់?

ស៊ីម : មួយទៀតឈ្មោះ ផាត់ ហ្នឹងទៅស្រុកកំណើតវិញទៅនៅឃុំព្រែកអំបិលហ្នឹងវិញ ទៅភូមិកូនជ្រៃវិញ ។

សេងគា : នៅកំពតហ្នឹង?

ស៊ីម : អត់ទេ!មិនមែននៅកំពតទេ ដល់ពេលទៅ៧៩ហ្នឹង យួនវៃហ្នឹងគាត់រត់ទៅចូលទៅភូមិកំណើតវិញទៅឃុំព្រែកអំបិលហ្នឹងវិញ ។

សេងគា : បាទ!

ស៊ីម : ចាំ!ហើយខ្ញុំប្ដូចម៉ោនេះម៉ោ ដាយព្រំដែនខាងបាត់ដំបងនេះ ។

សេងគា ៖ ចុះការរស់នៅ ការហូបចុកយ៉ាងម៉េចដែរមីង?

ស៊ីម ៖ កាលនៅអន្ទុភាពហ្នឹង?

សេងគា ៖ បាទ!

ស៊ីម ៖ កាលនៅអន្ទុភាពស្រែអំបិលហ្នឹងអត់មានបញ្ហាអីទេ គឺពេលវែកអំបិលយើងធ្វើអំបិលស្រែប្រាំង ខែប្រាំងអញ្ចឹងទៅវាថ្ងៃក្តៅខ្លាំង យើងត្រូវការអំបិលវាឡើង អំបិលហ្នឹងធ្វើម៉ោពីទឹកសមុទ្រ ការហូបអត់មានបញ្ហាអីទេ ម៉ោង១១ដល់ម៉ោងឡើងហូបបាយសិនទៅ គ្រាន់តែថាបាយយើងវាល់ចានហ្នឹង ចានយើងចានសំលកំពុងៗដែលហ្នឹង ម៉ាចានៗប៉ុនៗហ្នឹងល្មមតែយើងហូបឆ្អែតដែរហ្នឹង ប៉ុនគ្រាន់តែថាធ្វើការហត់នឿយ បន្តិច ។

សេងគា ៖ ចានសំល?

ស៊ីម ៖ អាចានយើងប៉ុនៗនេះ (គាត់ធ្វើកាយវិការដៃរបស់គាត់) ។

សេងគា ៖ បាទ!ម្នាក់ម៉ាចានមីង?

ស៊ីម ៖ ចាំ!ម្នាក់ចាន ។

សេងគា ៖ ហើយ១ថ្ងៃញុំាប៉ុន្មានពេលមីង?

ស៊ីម ៖ ១ថ្ងៃខ្ញុំ២ពេល ។

សេងគា ៖ ពេលថ្ងៃ នឹងពេលល្ងាច?

ស៊ីម ៖ ចាំ!ពេលម៉ោង១១ហ្នឹង នឹងពេលម៉ោង៥ឡើងពីធ្វើការ ។

សេងគា ៖ គេអត់មានធ្វើបាប គំរាមគំហែងអីទេ?

ស៊ីម ៖ អត់ទេ!ពេលយប់យើងវែកអំបិលហត់ទៅ ម៉ោង១១ហ្នឹងបបរសរឲ្យយើងហូបជាមួយត្រីប្រម៉ា អាត្រីយើងប្រមារធំៗហ្នឹងចំហុយហូបជាមួយបបរ ព្រោះអីយើងធ្វើការទាំងយប់ទាំងថ្ងៃ អត់មានពិបាកបបរវាវអីអត់ទេ ។

សេងគា ៖ បើឈឺមានពេទ្យមានអីមើលត្រឹមត្រូវ?

ស៊ីម ៖ ចាំ!បើសិនឈឺសម្រាកផ្ទះទៅ ពេទ្យម៉ោមើលដល់ផ្ទះក្នុងកងរបស់យើងហ្នឹង ។

សេងគា ៖ កាលហ្នឹងមីងមានគ្រួសារឬនៅ?

ស៊ីម ៖ នៅទេអត់ទាន់មានទេ ។

សេងគា ៖ គេអត់មានបង្ខំឲ្យយើងការទេមីង?

ស៊ីម ៖ អត់ទេ!ដល់អ្នកដែលគេចាស់ៗជាងយើង អាយុ២៥-២៦ទៅបានអន្ទុភាពហ្នឹងរៀបបើយើងនៅត្រឹមអាយុ២០-១៩អីអត់ទេ ។

សេងគា ៖ បាទ! ហើយមីងនៅពេលដែលម៉ោអញ្ចឹងមានដឹងដំណឹងពីអ្នកផ្ទះអីឪពុកម្ដាយ បងប្អូន យ៉ាងម៉េចទេ?

ស៊ីម ៖ ដឹងខ្ញុំខស្សាហ៍ទៅដែរ ។

សេងគា ៖ អ្ហូ! គេឲ្យទៅលេងដែរមីង?

ស៊ីម ៖ អ្ហូ! កាលពាន្នាំ?

សេងគា ៖ បាទ! កាលពាន្នាំអីហ្នឹង?

ស៊ីម ៖ ៧៥ ហើយ៧៩ហ្នឹងខ្ញុំអត់បានទៅលេងទេ ព្រោះខ្ញុំជាប់នៅធ្វើការងារឃ្លាំង រែកអំបិល ដល់ពេលបានរែកអំបិលតែពេលយប់ទេ ដល់ពេលថ្ងៃខ្ញុំធ្វើខាងសំណង់ ខាងឃ្លាំង អំបិល ខ្ញុំអត់បានចុះរែកអំបិលពេលថ្ងៃទេ ខ្ញុំនៅអន្ទភាពស្រែអំបិលមែន តែគេមាន ខាងសំណង់ ខាងកុមារ ខាងសិល្បៈ ចា៎! មានច្រើនផ្នែកណា ខាងកុមារ មានការងារ គេផ្ទេរទៅ ឯខាងសំណង់ព្រលឹមឡើងយើងគិតទៅតែសំណង់ទៅ អត់បានរែកអំបិល ទេ បានរែកតែយប់ ឆ្នៀតរែកតិចៗ ពេលយើងអស់កម្លាំងត្រូវការធ្វើការ យើងម៉ោ សម្រាកមុនគេបាន ។

សេងគា ៖ ចុះឪពុកម្ដាយវិញមីង គាត់បានប្រាប់ទេនៅពេលជួបគ្នាវិញ?

ស៊ីម ៖ ឪពុកម្ដាយពេលសម័យហ្នឹងគេបានទៅលេងផ្ទះគ្រប់គ្នា ខ្ញុំប្រញឹកធ្វើឃ្លាំងអត់បានទៅ ទេក្នុងកំឡុងពេលពាន្នាំហ្នឹងបានទៅ១ដងខាងខេត្តកណ្ដាលខ្ញុំ គេហៅតំបន់២៥ ហើយ តំបន់កំពង់ស្ពឺនេះតំបន់៣៣ គេហៅតំបន់ គេមិនហៅខេត្តទេជំនាន់ហ្នឹង ។

សេងគា ៖ បាទ! អញ្ចឹងមីងនៅធ្វើរហូតដល់ពេលបែកមីង?

ស៊ីម ៖ ចា៎! ដល់បែកដល់៧៥ហ្នឹង ។

សេងគា ៖ ហើយពេលដែលចេញពី៧៥ ម៉ោមីងក៏ អ្ហូ! ៧៩មីង?

ស៊ីម ៖ ចា៎! ម៉ោព្រំដែន យួនចូលខ្ញុំរត់ម៉ោ ។

សេងគា ៖ រត់ម៉ោតែឯងទៅ ?

ស៊ីម ៖ អត់ទេអន្ទភាព ម៉ោតាមអន្ទភាពម៉ោរហូត ឡើងភ្នំឡើងអីរហូតម៉ោ ហើយខ្លះក៏ដាច់ ដោចទៅក៏រត់ទៅខាងស្រុកកំណើតទៅ ។

សេងគា ៖ រត់កាត់ពីណាទៅណាដែរមីង កាលហ្នឹង?

ស៊ីម ៖ ពីយើង ចុះពីកំពតម៉ោៗខាងវាលវែងនេះ ។

សេងគា ៖ បាទ!

ស៊ុម ៖ ខានវាល់វែងអូរសោមយើងហ្នឹង ហើយម៉ោកោះកុងភ្នំឡើង១០០ ចុះ១០០ម៉ោតាមផ្លូវហ្នឹង មនុស្សស្លាប់ហូរហែរតាមផ្លូវហ្នឹងរហូត ហើយខ្ញុំចេះតែម៉ោជាមួយពួកទ័ពហ្នឹង មាំខែបួនថ្ងៃបានដល់ខ្លងយៃដល់ព្រំដែនថៃធ្វើដំណើរឡើងភ្នំហ្នឹង យប់ម៉ោង៥ ឈប់ហើយ ។

សេងគា ៖ ចេញពីស្រែអំបិលទៅ?

ស៊ុម ៖ ចា៎!ចេញពីស្រែអំបិលទៅយើង ។

សេងគា ៖ រហូតមកដល់ខ្លងយៃមីងនេះ?

ស៊ុម ៖ ចា៎!

សេងគា ៖ អស់រយៈពេល?

ស៊ុម ៖ ១ខែ ៤ថ្ងៃបានដល់ ។

សេងគា ៖ ដើររហូតមីង ដើរឆ្លងកាត់ភ្នំ?

ស៊ុម ៖ ដើរឡើងភ្នំ ចុះភ្នំ មានមេខ្យល់ដែលគាត់ធ្លាប់នៅសម័យ៥ឆ្នាំហ្នឹងគាត់ធ្វើការនៅតាមព្រំដែនហ្នឹងគាត់នាំផ្លូវ ។

សេងគា ៖ បាទ!គាត់ឈ្មោះអីគេមីង មីងស្គាល់ទេ?

ស៊ុម ៖ មិនដឹងឈ្មោះអីទេ គាត់ខាងម៉ង់រីណា៎ គាត់ជាអ្នកម៉ង់រី ហើយគាត់នៅតាមព្រំដែនហ្នឹង ហើយគាត់ស្គាល់ផ្លូវគាត់នាំ ផ្លូវមិនមានដូចផ្លូវយើងនេះអី ផ្លូវមាំដំណើរវែកតែព្រៃដើររហូត ។

សេងគា ៖ បាទ!នាំយើងម៉ោរហូត?

ស៊ុម ៖ ចា៎!

សេងគា ៖ មានគ្នាប្រហែលប៉ុន្មាននាក់កាលហ្នឹងម៉ោហ្នឹង?

ស៊ុម ៖ គ្នា២០០នាក់អីទៅទាំងអ្នកដឹកជញ្ជូន អ៊ុស៎!អ្នកកម្មករស្រែអំបិល ទាំងទ័ព ដល់ពេលអស់កម្លាំងយូរទៅខ្លះអត់បានដាក់បាយ ដាក់ទឹកម៉ោអត្ថុយតាមតែផ្លូវហ្នឹងរហូត មនុស្សរហូតមនុស្សអត់បាន ។

សេងគា ៖ បាទ!ប្រហែលជាប៉ុន្មានរយនាក់ ម៉ោទាំងអស់គ្នា?

ស៊ុម ៖ ម៉ោតាមផ្លូវផ្សេងៗគ្នា មិនមែនម៉ោប្រកតែមួយទេ ។

សេងគា ៖ បាទ!

ស៊ុម ៖ យើងចេញពីៗ យើងអន្តរភាពពីក្នុងម៉ោ ប៉ុនដោយខ្មែរក្រហមតែចំពោះពួកខ្ញុំប្រហែលជា ២០០នាក់អីដែរ ទាំងពួៗទាំងនារី ប៉ុនដល់ហើយចេះតែអស់កម្លាំងអត់អន្ករអីហូបម៉ោ នៅសល់ប្រហែល៣០នាក់មកដល់ខ្ទង់យ៉ៃ ស្លាប់តាមផ្លូវ មិនមែនម៉ោភ្លាមស្លាប់ភ្លាម ទេ អស់កម្លាំងអញ្ចឹងចេះតែអន្ទុយទៅ យើងមានកម្លាំងចេះតទៅទៀតអត់មានចាំអ្នក អន្ទុយទេ ព្រោះផ្លូវវាវែងឆ្ងាយនោះ ប្រហែលជា៣០នាក់ម៉ោដល់ខ្ទង់យ៉ៃ រំលោះ តាមផ្លូវរហូតអន្ទុយ ។

សេងគា ៖ មើលទៅម៉ោពីហ្នឹងរហូតប្រហែល១០០នាក់ ២០០នាក់ទៅដល់ទេ?

ស៊ុម ៖ ២០០នាក់អីនោះ ខ្សែដែលខ្ញុំម៉ោហ្នឹង ។

សេងគា ៖ ទាល់ម៉ោស្លាប់អស់នៅប្រហែល៣០នាក់?

ស៊ុម ៖ ម៉ោដល់ខ្ទង់យ៉ៃ នៅប្រហែលជា៣០នាក់ ប៉ុនមិនមែនយើងដឹងថាគាត់ស្លាប់ទេ តែ គាត់នៅអន្ទុយ ប៉ុនមិនរស់ទេ ព្រោះអីអត់មានទឹកអត់មានអន្ករទេ ។

សេងគា ៖ បាទ!ដល់សល់៣០នាក់ទៅ ចេញពីខ្ទង់យ៉ៃ ទៅនៅណាទៀត?

ស៊ុម ៖ ចូលខ្ទង់យ៉ៃៗ ទៅក៏មានរដ្ឋាភិបាល អុស៎!អ្នកដឹកនាំខ្មែរក្រហមយើងហ្នឹង ។

សេងគា ៖ បាទ!ឈ្មោះអី?

ស៊ុម ៖ ឈ្មោះតា ធឹម អញ្ចឹងចុះ ។

សេងគា ៖ បាទ!តាធឹមហ្នឹងគាត់ធ្វើអីគេមីង?

ស៊ុម ៖ ខាងកងពល ។

សេងគា ៖ គាត់ប្រធានកងពល?

ស៊ុម ៖ ចា៎!

សេងគា ៖ កងពលអីគេមីង?

ស៊ុម ៖ មិនដឹងកងពលលេខប៉ុន្មានទេនេះ ឈ្មោះតា ធឹម ហ្នឹង ម៉ោនៅហើយនៅចន្លោះនេះ ឈ្មោះ នី កន បានត្រូវ ដាក់ឈ្មោះ នី កនវិញ ។

សេងគា ៖ ឈ្មោះ នី កនវិញ?

ស៊ុម ៖ ចា៎!នី កន សព្វថ្ងៃហ្នឹងឥឡូវនៅខាង៣២ នាមត្រកូលគាត់ នី គាត់ឈ្មោះ កន ។

សេងគា ៖ គាត់ឥឡូវធ្វើអីមីង?

ស៊ីម ៖ គាត់ផ្លូវអាត្រែតហើយដឹង អូនឯងដែលព្រះទេផ្លូវហ្នឹងដែលសមាហរណកម្មហើយ គាត់ក៏នៅជាប់ជើងជាមួយរាជរដ្ឋាភិបាល ហើយកងពលពីកន្លែងមុននៅ៣២ហ្នឹង ប៉ុន្តែកងពល៣២០ ។

សេងគា ៖ គាត់ហ្នឹងអ្នកទៅជួយហៅមីងម៉ោ?

ស៊ីម ៖ គាត់ហ្នឹងអ្នកបណ្តុញទទួលខុសត្រូវ គាត់មានបណ្តុញកងវរៈ ដូចថាមានអ្នកដឹកនាំពីនោះម៉ោដែរ ។

សេងគា ៖ អ្ហូ!

ស៊ីម ៖ ក៏គាត់ចាត់ចែងឲ្យតាមថ្នាក់គាត់ហ្នឹងចុះទៅ ស្រាវជ្រាវយកយុវជនយុវនារីដែលមានវ័យពេញកម្លាំងហ្នឹង ដើម្បីយកម៉ោប្រមូលផ្តុំ នៅទីកន្លែងមួយដែលនៅតាមព្រំដែន ហ្នឹង ដើម្បីបង្កលក្ខណៈតស៊ូដឹកជញ្ជូនយុវជនធ្វើជាទ័ពដើម្បីតតាំងទៅទន្លេសាបយើង ហ្នឹង ហើយយុវនារីធ្វើជាអ្នកដឹកជញ្ជូន ចងក្រងជាទ័ព ជាកងដឹកជញ្ជូនអញ្ចឹង យក ម៉ោនៅក្នុងខ្វង់យៃហ្នឹងនៅបានកន្ទះខែទេ ជំរុំខ្វង់យៃហ្នឹងនៅក្នុងដីថៃ នៅបានកន្ទះខែក៏នាយកនហ្នឹងគាត់បញ្ជាឲ្យកម្លាំងរបស់យើងមានតួនាទីជាវរៈសេនាតូច វរៈសេនាធំអី ហ្នឹងស្រាវជ្រាវយកកម្លាំងយើងម៉ោវិញ គាត់ចែកអន្តរឲ្យយើងប៉ុន្មានម្នាក់ប៉ុន្មានការ ទេអាការយើង ជំនាន់ហ្នឹងមានការគេបើកពីចិននោះ ៣ការប្អូអីទេឲ្យជំរុំហ្នឹងម៉ោនៅនេះយើងព្រំដែនត្រាងនេះ នៅតាមអស់ហ្នឹងឯង ប៉ុនយើងគីឡូ១៣-គីឡូ១៨នោះនៅខាងយើងជិតផ្លូវទៅម៉ាឡៃនោះ ផ្លូវហ្នឹងគឺស្រុកភ្នំព្រឹក ។

សេងគា ៖ បាទ!

ស៊ីម ៖ ចាំ!ជម្រៀសខ្លួនម៉ោហ្នឹង កាលហ្នឹងខ្ញុំហើយនឹងមិត្តម៉ាចំនួនហ្នឹងនៅសុទ្ធតែព្រៃទាំងអស់ម៉ោគាត់យកម៉ោដាក់នៅតាមព្រៃហ្នឹង ធ្វើផ្ទះធ្វើ កាប់ព្រៃកាប់អី ចុះសុទ្ធតែព្រៃឈើ ម៉ងចាំ!នៅទៅកកើតកម្លាំងដឹកជញ្ជូនទៅ មានកងវរៈ មានវរៈសេនាតូចដូចកាលនៅសម័យយើង៣ឆ្នាំអញ្ចឹង ។

សេងគា ៖ ដល់ពេលមីងម៉ោបានកន្ទះខែម៉ោ មីងម៉ោតាមរយៈគា នី កន ហ្នឹងម៉ោនៅកន្លែង ហ្នឹង?

ស៊ីម ៖ ចាំៗ!នៅតាមព្រំដែនហ្នឹង ។

សេងគា ៖ ហើយមីងមានជួបហេតុការណ៍អីបន្ថែមទៀតទេ?

ស៊ីម ៖ ហេតុការណ៍រស់នៅដូចជាមិនមានហេតុការណ៍អីទេ គាត់អប់រំតាមកងតាមក្រុមហ្នឹង រហូតឲ្យដាំទឹកហូប ពយកយើងប្រើទឹកអូរ ហើយឲ្យដឹកអណ្តូងការពារសុខភាព ឲ្យដាំ ដំណាំហូប

កាប់ចំការកាប់ព្រៃ ឆ្លៀតពេលដែលទៅដឹកជញ្ជូនហ្នឹងកម្លាំងដែលម៉ោ សម្រាកហ្នឹងត្រូវកាប់ព្រៃហ្នឹងធ្វើ ដាំស្ពៃ ដាំត្រកួនហូបទៅ ហើយយើងនៅតាមអូរ បានយើងមានទឹក ព្រោះអត់មានស្អីដឹកទេ អត់មានអីដឹកអណ្ដូងដឹកអីទេ ព្រោះយើង អាចដឹកទឹងចបទឹងអីហ្នឹងតាមមាត់អូរហ្នឹងបាន យើងកុំយកទឹកអូរតែយើងយកតាម មាត់អូរៗអញ្ចឹង អាចជ្រាបទឹកហ្នឹងម៉ោអត់មានជាត់កំបោរ ហើយគាត់ឲ្យដាំ ដាំហូប អនាម័យ បត់ជើងតូចធំអី មានបង្គន់ មានដាំទឹកក្ដៅរហូត មានអនាម័យត្រឹមត្រូវ ណាស់ ហើយបើកអង្ករបើកអីឲ្យយើងហូប ទទួនខុសត្រូវ១០០ភាគរយតាំងពីឈឺ ពេលឈឺយើងសម្រាកទៅមានពេទ្យព្យាបាល ។

សេងគា ៖ ពេទ្យអីមានធម្មតា?

ស៊ីម ៖ មានធម្មតា ថ្នាំពេទ្យសំបូរហូរហៀរ ។

សេងគា ៖ ប៉ុន្ដែមីងស្គាល់ ម្នាក់ឯង មីងអត់បានជួបការលំបាកអីទេមីង?

ស៊ីម ៖ អត់ទេៗ ។

សេងគា ៖ ចុះបែរម៉ោឪពុកម្ដាយ បងប្អូនមីងវិញយ៉ាងម៉េចដែរ?

ស៊ីម ៖ បើឪពុកម្ដាយនៅខាងមូលដ្ឋាននោះវិញ ជួបការលំបាកច្រើនដែរ ហូបបបរដែរ ។

សេងគា ៖ អញ្ចឹងមីងជួបពួកគាត់នៅពេលណាដែរ ពេលបែករហូតម៉ោឆ្នាំណាបានជួបពួកគាត់?

ស៊ីម ៖ ទឹមពេលយើងសមាហរណកម្មហ្នឹងបានម៉ោលេង១ដងហ្នឹង ស្រួលបួលហើយហ្នឹង កាល សម័យ ។

សេងគា ៖ ឆ្នាំណាមីង?

ស៊ីម ៖ ហ៊ឺ!ឆ្នាំប៉ុន្មានទេ ។

សេងគា ៖ ៩៨ហើយ?

ស៊ីម ៖ ហ្នឹងហើយ៩៨ ។

សេងគា ៖ ដល់៩៨បានជួបគាត់?

ស៊ីម ៖ ចា៎!ចុះកាលយើងផ្ដាច់ខ្លួនហើយក្លាមអត់ហានចូលទេ ។

សេងគា ៖ ហើយកាលទៅ គាត់និយាយប្រាប់ពីរឿងអត់មានអីហូបអញ្ចឹងមីង?

ស៊ីម ៖ គាត់មិនដែលនិយាយផង ។

សេងគា ៖ ធ្វើម៉េចបានមីងដឹងថាគាត់អត់អីហូប?

ស៊ីម ៖ ព្រោះអីឪពុកខ្ញុំស្លាប់ហើយ ខ្ញុំទៅហ្នឹងឪពុកស្លាប់នៅតែម្ដាយ ហើយម្ដាយខ្ញុំគាត់?

សេងគា ៖ អ្ហូ!ឪពុកស្លាប់កាលសម័យខ្មែរក្រហមដែរ?

ស៊ីម ៖ ចា៎!

សេងគា ៖ ស្លាប់ដោយសារជំងឺ ឬដោយសារអត់អីហូប?

ស៊ីម ៖ អត់ទេ ស្លាប់នឹងជំងឺព្រោះអីគាត់ធ្វើការច្រើនពេកទៅ ខ្សោយបេះដូង ធ្វើការចិញ្ចឹម កូនៗ

សេងគា ៖ កាលស្លាប់មីងអត់ដឹងទេ ទាល់តែពេលមីងទៅបានដឹងមីង?

ស៊ីម ៖ ចា៎!ខ្ញុំអត់ដឹង ខ្ញុំនៅនេះហ្នឹងៗ

សេងគា ៖ មីងដឹងថាគាត់ស្លាប់នៅឆ្នាំ៧០ប៉ុន្មានទេ?

ស៊ីម ៖ មិនដឹងឆ្នាំ៧០ប៉ុន្មានទេ មិន៧០ទេ ៩០នេះហើយ មុនខ្ញុំទៅលេង៣ឆ្នាំនេះហ្នឹងៗ

សេងគា ៖ អ្ហូ!កាលសម័យខ្មែរក្រហមអត់អីទេ?

ស៊ីម ៖ អត់អីទេៗ

សេងគា ៖ គ្រាន់តែហូបបបរអីតិចតួចតែអត់មានគេធ្វើបាបទេ?

ស៊ីម ៖ អត់ទេៗ

សេងគា ៖ សាច់ញាតិមីងនៅជិតហ្នឹង អត់អីដែរ?

ស៊ីម ៖ អត់អីដែរ មិនដែលគេធ្វើបាបទេ ប៉ុនហូបបបរជាទូទៅហើយ ក្នុងហាករណ៍មួយៗ នោះៗ

សេងគា ៖ បាទ!បកក្រោយបន្តិចមីង នៅពេលដែលមីងម៉ោនៅជាមួយតាកន ហ្នឹង តាកន គាត់ធ្វើប្រធានកងពល?

ស៊ីម ៖ ចា៎!

សេងគា ៖ តែម៉ោពេលបច្ចុប្បន្នគាត់ធ្វើអីដែរមីង?

ស៊ីម ៖ តួនាទីឥឡូវមិនដឹងអីទេ ខ្ញុំមិនបានដឹងដែរ នៅតែកងពលដដែលមិនដឹង ប៉ុនគាត់អាចចាស់ទៅគាត់រ៉ិត្រែតហើយៗ

សេងគា ៖ អញ្ចឹងគាត់នៅរស់ទេ ផ្ទះគាត់នៅឯណាមីង?

ស៊ីម ៖ នៅ៣២នេះ នៅខាងភ្នំព្រឹកនេះៗ

សេងគា ៖ គាត់នៅស្រុកភ្នំព្រឹកមីង?

ស៊ីម ៖ ភ្នំព្រឹកហ្នឹងហើយ សំពៅលូន ភ្នំព្រឹកជាប់នឹងកំរៀងនេះទេ ខាងនោះខាងសំពៅលូន ខាងជាប់ម៉ាឡៃនោះ ៣២ហ្នឹង ចូលក្នុងស្រុកៗសំពៅលូនហើយៗ

សេងគា ៖ គាត់ប្រហែលអាយុប៉ុន្មានហើយមីង?

ស៊ីម ៖ ៧០ហើយ ចាស់ហើយៗ

សេងគា ៖ ឈ្មោះ គាត់នៅដាក់ឈ្មោះ នី កន ហ្នឹងដដែលទេ?

ស៊ីម ៖ ចា៎!

សេងគា ៖ នៅពេលមីងនៅហ្នឹងមីងមានដែលទៅប្រយុទ្ធជាមួយកងទ័ពវៀមណាមទេ?

ស៊ីម ៖ មិនប្រយុទ្ធក៏ដូចប្រយុទ្ធដែរ ព្រោះដឹកជញ្ជូន ។

សេងគា ៖ មីងដឹកជញ្ជូន?

ស៊ីម ៖ ចា៎!ដឹកជញ្ជូន ។

សេងគា ៖ ដឹកជញ្ជូនមានកាន់កាំភ្លើងកាន់អីទេ?

ស៊ីម ៖ អត់ទេ គ្រាន់តែដឹកជញ្ជូនគ្រាប់ ដឹកជញ្ជូនអង្ករ ឲ្យទ័ពយើងហ្នឹង ។

សេងគា ៖ ពីណាទៅណាមីង?

ស៊ីម ៖ ពីយើងខ្លែនហ្នឹង ។

សេងគា ៖ ខ្លែនទៅណាវិញ?

ស៊ីម ៖ ទៅខាងតាឡូងបាត់ដំបងនោះខាងទន្លេសាប ទៅខាងខ្សាយទៅខាងអីនោះណា ។

សេងគា ៖ ខាងក្បាលខ្មោចហ្នឹង?

ស៊ីម ៖ ខាងតាឡូងបាត់ដំបងមិនដឹង ។

សេងគា ៖ ក្បាលខ្មោច?

ស៊ីម ៖ ចា៎!

សេងគា ៖ ដល់ពេលធ្វើអញ្ចឹងរយៈពេលប៉ុន្មានឆ្នាំមីងបាននេះ ប្រយុទ្ធគ្នា បាញ់គ្នាហ្នឹង?

ស៊ីម ៖ អេស៎!ប៉ុន្មានឆ្នាំទេ សមាហរណកម្មទៅក៏ចប់ទៅ ។

សេងគា ៖ រហូតដល់៩៨អញ្ចឹង?

ស៊ីម ៖ ចា៎!

សេងគា ៖ ហើយមីងមានគ្រួសារនៅឆ្នាំណា?

ស៊ីម ៖ ឆ្នាំ៨៦ ។

សេងគា ៖ អ្ហូ!៨៦បានមីងយកគ្រួសារមីង?

ស៊ីម ៖ ចា៎!ខ្ញុំម៉ោនៅអង្គភាពខាងគ្រួសារខ្ញុំ ព្រោះគ្រួសារខ្ញុំនៅជាមួយលោក សុខ គង់ ។

សេងគា ៖ អ្ហូ!

ស៊ីម ៖ ចា៎!ហើយខ្ញុំនៅខាងដឹកជញ្ជូននៅជាមួយលោក នី កន ។

សេងគា ៖ អ្ហូ!អញ្ចឹងនៅបែកគ្នាមីង?

ស៊ីម : ចា៎!អញ្ជឹងគូរដណ្ដឹងហ្នឹង១ឆ្នាំ ២ឆ្នាំហើយ ដល់យើងចាស់ៗអញ្ជឹងអាយុ២៤-២៨ គាត់រៀបចំឲ្យយើង មិនមានភ្លេងមិនមានភ្ជាត់អីបានត្រឹមត្រូវទេកាលហ្នឹង ។

សេងគា : អញ្ជឹងក៏ជួបគ្នាទៅមីង បានជាប្ដីប្រពន្ធ?

ស៊ីម : ចា៎!

សេងគា : អញ្ជឹងដណ្ដឹង២ឆ្នាំមុនហើយបានការនៅឆ្នាំ៨៨ អញ្ជឹងដណ្ដឹងតាំងពី៨៦?

ស៊ីម : ចា៎ៗ!

សេងគា : គាត់ក៏រៀបការឲ្យទៅមីង?

ស៊ីម : ចា៎!គាត់រៀបចំឲ្យមេ ហើយដឹកនាំអង្គភាព ។

សេងគា : ចុះប្ដីមីងនៅខាងលោកពូ សុខ គង់ គាត់ធ្វើអីដែរ?

ស៊ីម : អេស៎!លោក សុខ គង់ហ្នឹងអភិបាលខេត្តយើង ។

សេងគា : បាទៗ!

ស៊ីម : ចា៎!ប្ដីខ្ញុំគ្រូសារខ្ញុំហ្នឹងខាងប្រធានរដ្ឋបាល នៅជាមួយគាត់ស្មៀនគាត់ហ្នឹង ។

សេងគា : អ្ហូ!ប្រធានរដ្ឋបាល?

ស៊ីម : ចា៎!

សេងគា : នៅស្រុកហ្នឹង ពីមុននៅស្រុក?

ស៊ីម : ចា៎!កាលនៅទ័ព គាត់នៅខាងទូរលេខ ខាងបកសារ ។

សេងគា : ដល់ពេលយកទៅខេត្តទៅជាមួយដែរ?

ស៊ីម : អត់ទេ!គាត់ស្លាប់ហើយ គាត់ស្លាប់បាន១ឆ្នាំនេះហើយ ។

សេងគា : ទើមស្លាប់បានមួយឆ្នាំទេ?

ស៊ីម : ចា៎!គាត់ ។

សេងគា : គាត់ស្លាប់ដោយសារអីមីង?

ស៊ីម : គាត់ឈឺ ធ្វើការអត់គិតមើលខ្លួន ពោះវៀនក្រពះ ដល់ពេលធ្ងន់ទៅមើលអត់ជា ។

សេងគា : អ្ហូ!ប្ដីមីងឈ្មោះអីដែរមីង?

ស៊ីម : ខាន់ សំអុន ។

សេងគា : ខាន់ សំអុន?

ស៊ីម : ចា៎!ប្រធានរដ្ឋបាលខាងស្រុកកំរៀងគេចូលគាត់មុនគេ ហើយបានចូលអភិបាលស្រុក ។

សេងគា : ហើយមីងមានកូនប៉ុន្មាននាក់ដែររាល់ថ្ងៃ?

ស៊ីម ៖ កូនមានតែ១នាក់ ។

សេងគា ៖ អ្ហូ!មានតែ១នាក់ ប្រុសឬស្រីមីង?

ស៊ីម ៖ ប្រុស ។

សេងគា ៖ ឥឡូវអាយុប៉ុន្មានហើយ កូនមីង?

ស៊ីម ៖ អាយុ២៣ហើយ ចូលឆ្នាំថ្មីនេះ២៤ហើយ ។

សេងគា ៖ ទាល់រៀបការហើយ ចាប់ដៃនៅជាមួយគ្នាម៉ោរហូត ទល់ពេលធ្វើសមាហរណកម្មបាន ទៅលេងផ្ទះទាំងអស់គ្នា?

ស៊ីម ៖ សមាហរណកម្មបានទៅផ្ទះ១ដង ។

សេងគា ៖ ប្ដីមីងទៅជាមួយដែរ ឬអត់ទៅទេ?

ស៊ីម ៖ ចាំ!ទៅ ទៅលេងខាងគាត់បានមួយដឹង តាកែវ គាត់នៅតាកែវ ។

សេងគា ៖ អ្ហូ!គាត់នៅតាកែវ?

ស៊ីម ៖ ចាំ!

សេងគា ៖ ទឹមស្លាប់បានមួយឆ្នាំទេមីង?

ស៊ីម ៖ ចាំ!ទឹមម៉ាខួបខែ១០ នេះឯង ។

សេងគា ៖ បាទ!ដល់អញ្ចឹងមីងនៅតស៊ូនៅហ្នឹងរហូតធ្វើអីដែរមីង កាលពេលមីងនៅក្នុងទ័ពមីង ធ្វើអីខ្លះដែរ កាលតាំងពី៧៩-៨០រហូតបានគ្រួសារមីង?

ស៊ីម ៖ ធ្វើចំការតិចតួចណាស់ កាលគាត់នៅសម្រ្គាមគាត់ទៅទន្លេបានធ្វើចំការធ្វើអីទៅ ។

សេងគា ៖ អ្ហូ!បានទៅជាមួយសុខ គង់ គាត់ធ្វើចំការជាមួយសុខ គង់ទៅ?

ស៊ីម ៖ ចាំ!ទៅទន្លេ ។

សេងគា ៖ ទាល់មីងបែកគ្នាទៅ?

ស៊ីម ៖ ចាំ!

សេងគា ៖ នៅជាមួយ នី កន នៅខាងនី កនទៅ?

ស៊ីម ៖ ចាំ!ប៉ុន្តែអត្តភាពយើងម៉ោនៅជាមួយខាងប្ដីហើយ នៅជាមួយ នី កន គឺនៅការដឹកជញ្ជូនទេ ។

សេងគា ៖ នៅមិនទាន់រៀបការទេ?

ស៊ីម ៖ ចាំៗ!

សេងគា ៖ ដល់ពេលរៀបការហើយម៉ោនៅជាមួយសុខ គង់ទាំង២នាក់?

ស៊ីម ៖ ចា៎!ម៉ោនៅអន្តកាពជាមួយប្តី ខាងលោក សុខ គង់ នៅខាងយើងភ្លើងឆេះហ្នឹង ឥឡូវហ្នឹងនៅឯភ្នំព្រឹកនោះ កាលនៅដឹកជញ្ជូន ។

សេងគា ៖ អ្ហ៊ូ!កាលមីងដឹកជញ្ជូនៗនៅភ្នំព្រឹកមីង?

ស៊ីម ៖ ចា៎!ហៅគីឡូ១៣ គីឡូ១៨មិនទាន់មានភូមិមានផ្ទះថ្មអីទេ នៅព្រៃ ។

សេងគា ៖ បាទ!នៅព្រៃនៅឡើយទេ?

ស៊ីម ៖ ចា៎!ទាល់តែពេលបានប្តីទៅក៏តាមប្តីម៉ោនេះវិញ ។

សេងគា ៖ ដល់ពេលបានមោ៉ដល់នេះមានប្តីទៅក៏ម៉ោនៅនេះទៅ ធ្វើផ្ទះធ្វើអីទៅ?

ស៊ីម ៖ ចា៎!មានប្តីហ្នឹង ក្នុងកំឡុងយើងនៅភ្លើងឆេះនោះដែរ ។

សេងគា ៖ អ្ហ៊ូ!

ស៊ីម ៖ ទឹមយើងមុនសមាហរណកម្ម១ឆ្នាំ ២ឆ្នាំ យើងនាំគ្នាម៉ោនៅនេះ ប៉ុនប្តីក៏នៅមុខដែរ ប្តីនៅទន្លេនោះដែរ ប៉ុនមិនទាន់សមាហរណកម្មទេ ។

សេងគា ៖ ផ្ទះមីងនៅណានេះ?

ស៊ីម ៖ នេះផ្ទះខាងលិចនេះ ខាងលិចជាប់នេះ ។

សេងគា ៖ ដល់ពេលបែកនេះហើយមីងម៉ោធ្វើអីនេះវិញ ឬក៏អត់ធ្វើអីទេ?

ស៊ីម ៖ ខ្ញុំអត់មានធ្វើអីទេ ។

សេងគា ៖ ប៉ុន្តែប្តីមីងនៅជាមួយឯកឧត្តម សុខ គង់រហូតដែរ?

ស៊ីម ៖ ចា៎!ដល់ពេលគាត់មានតួនាទីទៅខេត្តទៅ គាត់ក៏នៅក្នុងស្រុកនេះ លោកសុខ គង់ គាត់ជាប់ជាអភិបាលខេត្តជាប់២-៣ដែរ អភិបាលស្រុកថ្មីចុះម៉ោនៅស្រុកថ្មីនេះ ។

សេងគា ៖ បាទ!អញ្ចឹងបងប្អូនមីងកើតទាន់សម័យប៉ុល ពត ទាំងអស់មីង?

ស៊ីម ៖ ទាន់ទាំងអស់ ប៉ុនទាស់គ្រាន់តែនៅកុមារ អត់បាន ។

សេងគា ៖ កាលហ្នឹងមីងទៅលេងឪពុកម្តាយមីង ឪពុកម្តាយមីងអត់បាននិយាយថាពិបាកម៉េចប្អូនយកទៅណាទៅណីទេ គាត់អត់បាននិយាយ ឬក៏មីងអត់បានសួរដែរឬម៉េច?

ស៊ីម ៖ ខ្ញុំអត់បានសួរគាត់ទេ គាត់ចាស់ដែលហើយ ទៅលេងបានតិចទៅដើរលេងផ្ទះបងប្អូនមិនសព្វផង ។

សេងគា ៖ រហូតដល់គាត់ស្លាប់អត់ទៀត?

ស៊ីម ៖ ស្លាប់!ខ្ញុំទៅនៅម្តាយ ហើយ១ឆ្នាំម្តាយខ្ញុំស្លាប់ទៀត ។

សេងគា ៖ អញ្ចឹងចុងក្រោយមីងមានអ៊ីចង់សួរខ្ញុំវិញទេមីង?

ស៊ីម ៖ ដូចអត់មានអីចង់សួរវិញផង ។

សេងគា ៖ អញ្ចឹងខ្ញុំអរគុណមីងច្រើនហើយមីង ។

ស៊ីម ៖ ចា៎ៗ !

**ចប់**